Brakas3

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៤ សហវ

ភ្នំពេញ,ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង

# ស្តីពីគោលការណ៍សំរាប់ហ្វឹកហាត់ និង ការប្រកួតកីឡា ជាផ្លូវការគ្រប់ប្រភេទប្រចាំឆ្នាំ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត.១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ រកម ០១.៩៩.០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការប្រព្រឹត្តទៅ នៃ កិច្ចលទ្ធកម្មចំពោះ ក្រសួងអាទិភាពទាំងបួន

-បានឃើញលិខិតលេខ ៣៥៩៧ សហវ.ថហ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញសេចក្តីជូនដំណឹងលេខ ៣៧៤ សជណ.ហវ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលកំណត់គោលការណ៍ប្រាក់បំប៉នកីឡាករ ប្រាក់បំប៉នគណៈកម្មាធិការ និង ក្រុមកីឡាករ

-បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

-អនុលោមតាមតំរូវការចាំបាច់ និង ជាក់ស្តែងចំពោះមុខ

# សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**ប្រការ ១ :** ដើម្បីធានាគុណភាពក្នុងការបំប៉ន និង លើកទឹកចិត្តដល់ក្រុមកីឡា និង កីឡាករ ដែលបានខិតខំចូលរួមយ៉ាងច្រើនកុះករ ក្នុងបណ្តាសកម្មភាពប្រកួតជាផ្លូវការនៅក្នុងប្រទេស នៅគ្រប់ស្រទាប់មហាជន សិស្ស និស្សិត តាមលំដាប់ថ្នាក់ចាប់ពីការប្រកួតជ្រើសរើសជើងឯក ប្រចាំភូមិភាគ ជ្រើសរើសជើងឯកទូទាំងប្រទេស និង ត្រៀមចូលរួមប្រកួត ជាលក្ខណៈអន្តរជាតិប្រចាំឆ្នាំនិមួយៗ ក្រសួងអប់រំ យុវជន និង កីឡា ត្រូវចាត់ចែងបំផុសកីឡាតាមគ្រប់រូបភាព ពិសេសសកម្មភាពប្រកួត ។

**ប្រការ ២ :** ការប្រកួតកីឡាជាផ្លូវការគ្រប់ប្រភេទ និងការហ្វឹកហាត់ ដែលអាចទទួលការធានាចំណាយពីរដ្ឋមានដូចខាងក្រោម:

**ក. ការប្រកួតកីឡា (ក្រោមការគ្រប់គ្រងពីក្រសួងអប់រំ យុវជន និង កីឡា):**

១-ជ្រើសរើសជើងឯកកីឡាមហាជនប្រចាំឆ្នាំនៅតាមភូមិភាគ

២-ជ្រើសរើសជើងឯកកីឡា សិស្សបឋមសិក្សា ទូទាំងប្រទេស

៣-ជ្រើសរើសជើងឯកកីឡា សិស្សមធ្យមសិក្សា ទូទាំងប្រទេស

៤-ជ្រើសរើសជើងឯកកីឡា និស្សិតឧត្តមសិក្សា និង មធ្យមសិក្សាឯកទេស ទូទាំងប្រទេស

៥-ជ្រើសរើសជើងឯកកីឡា មហាជន ទូទាំងប្រទេស

៦-ប្រកួតអន្តរជាតិលក្ខណៈជាម្ចោម

**ខ. ការហ្វឹកហាត់ :**

ការប្រមូលផ្តុំកីឡាករជំរើសជាតិហ្វឹកហាត់ សំរាប់ត្រៀមលក្ខណៈប្រកួតកីឡាដណ្តើម ពានរង្វាន់ជាលក្ខណៈអន្តរជាតិ ជាសមត្ថកិច្ចរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**គ. ការប្រកួតកីឡា ( ក្រោមការគ្រប់គ្រងរបស់ខេត្ត-ក្រុង ) :**

- ការប្រកួតជ្រើសរើជើងឯកកីឡាមហាជន កីឡាសិស្សបឋមសិក្សា កីឡាសិស្សមធ្យមសិក្សា នៅតាមខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ។

- ការប្រមូលផ្តុំកីឡាករជំរើសខេត្ត-ក្រុង ដើម្បីត្រៀមលក្ខណៈប្រកួតជ្រើសរើសជើង ឯកទូទាំងប្រទេស ជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង ។

Brakas3

- ថវិកាចំណាយសំរាប់ការប្រកួតកីឡា និងការប្រមូលផ្តុំកីឡាករនៅតាមខេត្ត-ក្រុង ជាបន្ទុករបស់មន្ទីរអប់រំ យុវជននិង កីឡាខេត្ត-ក្រុង ។

**ប្រការ ៣ :** ការប្រកួតកីឡាក្នុងប្រទេសជាផ្លូវការ ត្រូវមានការអនុញ្ញាតពីក្រសួង ដែលគ្រប់គ្រងវិស័យកីឡា នឹងត្រូវបង្កើតគណៈកម្មការ និង អនុគណៈកម្មការផ្សេងៗ សំរាប់ទទួលខុសត្រូវ ដែលទទួលស្គាល់ដោយស្ថាប័ននោះ ។

**ប្រការ ៤ :** តួនាទី និង ភារកិច្ច របស់គណៈកម្មការនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូកទី ២

## ការរៀបចំគណៈកម្មការ និង ការចាត់តាំងអ្នកជំនាញបច្ចេកទេស

**ប្រការ ៥ :** ចំពោះការប្រកួតកីឡាក្នុងប្រទេស ត្រូវរៀបចំគណៈកម្មការ អនុគណៈកម្មការ និង ក្រុមជំនាញផ្សេងៗដូចខាងក្រោម :

**ក- គណៈកម្មការ :**

- គណៈកម្មការទទួលបន្ទុករួម
- គណៈកម្មការរៀបចំការប្រកួត
- លេខាធិការដ្ឋានអចិន្ត្រៃយ៍

**ខ- អនុគណៈកម្មការបច្ចេកទេសមាន :**

- ក្រុមអាជ្ញាកណ្តាល និង ចៅក្រម
- ក្រុមតាមដានបច្ចេកទេស
- ក្រុមលេខាតុប្រកួត

**គ- អនុគណៈកម្មការគ្រប់គ្រងទីលាន :**

- ក្រុមរៀបចំទីលាន
- ក្រុមរៀបចំឧបករណ៍បច្ចេកទេស
- ក្រុមរៀបចំវេទិកា

**ឃ- អនុគណៈកម្មការសុខភាពមាន :**

- ក្រុមសង្គ្រោះបន្ទាន់
- ក្រុមត្រួតពិនិត្យដូភីង និង យ៉េនឌ័រ
- ក្រុមពេទ្យ

ខ. អនុគណៈកម្មការបដិសណ្ឋារកិច្ច និង ពត៌មាន :

- ក្រុមបើក បិទពិធី និង ពិធីការ
- ក្រុមពត៌មាន

ច. អនុគណៈកម្មការហិរញ្ញវត្ថុមាន :

- ក្រុមគណនេយ្យ
- ក្រុមសំភារៈ និង រង្វាន់
- ក្រុមដឹកជញ្ជូន

ឆ. អនុគណៈកម្មការសន្តិសុខមាន :

- ក្រុមសណ្តាប់ធ្នាប់ទីលានប្រកួត
- ក្រុមសណ្តាប់ធ្នាប់កន្លែងស្នាក់នៅ
- ក្រុមសណ្តាប់ធ្នាប់ពេលបើក និង បិទពិធី

## ជំពូកទី ៣

## ការប្រើប្រាស់មន្ត្រីរាជការ និង អ្នកជំនាញបច្ចេកទេស

**ប្រការ ៦ :**

ក. ការប្រកួតជ្រើសរើសជើងឯកកីឡាមហាជន នៅតាមខេត្ត/ក្រុង មាន បាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្ម ត្រូវកំណត់ដោយលិខិតបង្គាប់ការ ថ្នាក់ខេត្ត/ក្រុងស្របតាមការណែនាំ របស់ក្រសួង ។

ខ. ការប្រកួតជ្រើសរើសជើងឯកកីឡាសិស្សបឋមសិក្សា និង មធ្យមសិក្សា នៅតាមខេត្ត/ក្រុង មានបាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្ម ត្រូវកំណត់ដោយលិខិតបង្គាប់ការថ្នាក់ខេត្ត/ក្រុង ស្របតាមការណែនាំ របស់ក្រសួង ។

គ. សមាសភាពនៃគណៈកម្មការ និង អនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសចេញពីថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៅក្នុងមូលដ្ឋានខេត្ត-ក្រុង ដែលរៀបចំការប្រកួតកីឡាឱ្យអស់លទ្ធភាព ទើបអាចប្រើប្រាស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការឆ្លងខេត្ត-ក្រុងបាន ។

ឃ. ការប្រកួតជ្រើសរើសជើងឯកប្រចាំឆ្នាំនៃវិញ្ញាសាកីឡាផ្សេងៗ ដែលស្នើឡើងដោយសហព័ន្ធនានា ក្រៅពីបាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្ម ត្រូវឆ្លងតាមឋានានុក្រមជំនាញ ។ ការប្រើប្រាស់ថវិកា និង មន្ត្រី បច្ចេកទេស ជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ៧ :** និយាមនៃការប្រើប្រាស់មន្ត្រីរាជការ អ្នកជំនាញ និង បច្ចេកទេសក្នុងការប្រកួត បាល់ទាត់ បាល់ទះ បាល់បោះ អត្តពលកម្ម និង វិញ្ញាសាដទៃទៀត ត្រូវរៀបចំតាមអត្រា ដូចខាងក្រោម:

| ល.រ | ១-ការប្រកួតជ្រើសរើសជើងឯកកីឡាសិស្សបឋម និង មធ្យមសិក្សាទូទាំងប្រទេស | ២-ការប្រកួតជ្រើសរើសជើងឯកកីឡាសិស្សឧត្តមសិក្សា និង មធ្យមសិក្សាឯកទេស ទូទាំងប្រទេស | ៣-ការប្រកួតជ្រើសរើសជើងឯកកីឡាយុវជនប្រចាំឆ្នាំតាមភូមិភាគ | ៤-ការប្រកួតជ្រើសរើសជើងឯកកីឡាយុវជនទូទាំងប្រទេស |
|---|---|---|---|---|
| ក | **គណៈកម្មការ** | | | |
| - | ក/ការទទួលបន្ទុករួមយ៉ាងច្រើន ៧នាក់ | -ក/ការទទួលបន្ទុករួមយ៉ាងច្រើន ៧ នាក់ | -ក/ការទទួលបន្ទុករួមយ៉ាងច្រើន ៧ នាក់ | -ក/ការទទួលបន្ទុករួមយ៉ាងច្រើន ៧ នាក់ |
| - | គ/ការរៀបចំការប្រកួតយ៉ាងច្រើន១៥ នាក់ | -គ/ការរៀបចំការប្រកួតយ៉ាងច្រើន១៥នាក់ | -គ/ការរៀបចំការប្រកួតយ៉ាងច្រើន១៥នាក់ | -គ/ការ រៀបចំការប្រកួតយ៉ាងច្រើន១៣នាក់ |
| - | លេខាអចិន្ត្រៃយ៍យ៉ាងច្រើន១៧ នាក់ | -លេខាអចិន្ត្រៃយ៍យ៉ាងច្រើន១៧ នាក់ | -លេខាអចិន្ត្រៃយ៍យ៉ាងច្រើន១០ នាក់ | -លេខាអចិន្ត្រៃយ៍ យ៉ាងច្រើន១០ នាក់ |
| ខ | **អនុគណៈកម្មការបច្ចេកទេស** | | | |
| 1 | **ផ្នែកបាល់ទាត់** | | | |
| - | អាជ្ញាកណ្តាល ១នាក់/កីឡាករ ២៧ នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ១៤នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ១២នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ៨នាក់ |
| - | អ្នកតាមដានបច្ចេកទេស១នាក់/កីឡាករ២៨ នាក់ | -អ្នកតាមដានបច្ចេកទេស ២នាក់/១ទីលាន | -អ្នកតាមដានបច្ចេកទេស ១នាក់ /១ទីលាន | -អ្នកតាមដានបច្ចេកទេស ២នាក់/១ទីលាន |
| - | លេខាតុប្រកួត ២នាក់ / ១ទីលាន | -លេខាតុប្រកួត ២នាក់ / ១ទីលាន | -លេខាតុប្រកួត ១នាក់ / ១ទីលាន | -លេខាតុ-ជំនួយការអាជ្ញាកណ្តាល ២នាក់/១ទីលាន |
| 2 | **ផ្នែកបាល់ទះ** | | | |
| - | អាជ្ញាកណ្តាល ១នាក់/កីឡាករ ៤៨ នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ ១២ នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ ១២ នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ ១២ នាក់ |
| - | អ្នកតាមដានបច្ចេកទេស១នាក់/កីឡាករ៧២ នាក់ | -អ្នកតាមដានបច្ចេកទេស២នាក់/១ទីលាន | -អ្នកតាមដានបច្ចេកទេស ១នាក់ /១ទីលាន | -អ្នកតាមដានបច្ចេកទេស ២នាក់/១ទីលាន |
| - | ចៅក្រម ១នាក់ / កីឡាករ ២៨នាក់ | -ចៅក្រម ១នាក់ / កីឡាករ ១២នាក់ | -ចៅក្រម ១នាក់ / កីឡាករ ១២នាក់ | -ចៅក្រម ៤នាក់ / ១ទីលាន |
| | -លេខាតុប្រកួត ២នាក់ /១ទីលាន | -លេខាតុប្រកួត ២នាក់ /១ទីលាន | -លេខាតុប្រកួត ២នាក់ /១ទីលាន | -លេខាតុប្រកួត ២នាក់ /១ទីលាន |
| 3 | **ផ្នែកបាល់បោះ** | | | |
| - | អាជ្ញាកណ្តាល ១នាក់/កីឡាករ ៣៦ នាក់ | -អាជ្ញាកណ្តាល ១នាក់/កីឡាករ៦ នាក់ | -អាជ្ញាកណ្តាល ១នាក់ /កីឡាករ១២ នាក់ | -អាជ្ញាកណ្តាល ១នាក់ /កីឡាករ៥ នាក់ |
| - | អ្នកតាមដានបច្ចេកទេស១នាក់/កីឡាករ៣៦នាក់ | -អ្នកតាមដានបច្ចេកទេស២នាក់/១ទីលាន | -អ្នកតាមដានបច្ចេកទេស១នាក់ / ១ទីលាន | -អ្នកតាមដានបច្ចេកទេស៤នាក់ /១ទីលាន |
| - | លេខាតុប្រកួត ១នាក់ /កីឡាករ ៣៦នាក់ | -លេខាតុប្រកួត ៤នាក់ / ១ទីលាន | -លេខាតុប្រកួត ៤ នាក់ /១ទីលាន | -លេខាតុប្រកួត ៤ នាក់ /១ទីលាន |
| 4 | **ផ្នែកអត្តពលកម្ម** | | | |
| - | អ្នកតាមដានបច្ចេកទេស១នាក់/១វិញ្ញាសា | -ចៅក្រម ១នាក់ / កីឡាករ ១០ នាក់ | -ចៅក្រម ១នាក់ / កីឡាករ ១២ នាក់ | -ចៅក្រម ១នាក់ / កីឡាករ ៤ នាក់ |
| - | លេខាតុប្រកួត ១នាក់ /១វិញ្ញាសា | -លេខាតុប្រកួត ១នាក់ /១វិញ្ញាសា | -លេខាតុប្រកួត ១នាក់ /១វិញ្ញាសា | -លេខាតុប្រកួត ១នាក់ /១វិញ្ញាសា |
| - | ចៅក្រម ១នាក់ / កីឡាករ ១១ នាក់ | | | -អ្នកតាមដានបច្ចេកទេស១នាក់ /១ទីលាន |
| 5 | **វិញ្ញាសាដទៃទៀត** | | | |
| | | | | -អាជ្ញាកណ្តាល ១នាក់/កីឡាករ៨នាក់ |
| | | | | -អ្នកតាមដានបច្ចេកទេស ២នាក់/១ទីលាន |
| | | | | -លេខាតុយ៉ាងច្រើន៥នាក់ |

| | | | | |
|---|---|---|---|---|
| | | | | -ចៅក្រម១នាក់/កីឡាករ១៦នាក់ |
| គ | **អនុគណៈកម្មការគ្រប់គ្រងទីលាន** | | | |
| | **១.ផ្នែកបាល់ទាត់** | | | |
| - | ក្រុមរៀបចំទីលានបាល់ទាត់ ៦នាក់ /១ទីលាន | -ក្រុមគ្រប់គ្រងទីលាន ៦នាក់ /១ទីលាន | -ក្រុមគ្រប់គ្រងទីលាន ៤នាក់ /១ទីលាន | -ក្រុមគ្រប់គ្រងទីលាន ៦នាក់ /១ទីលាន |
| - | ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស១នាក់/១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់/១ទីលាន |
| - | ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ |
| | **២.ផ្នែកបាល់ទះ** | | | |
| - | ក្រុមរៀបចំទីលានបាល់ទះ ៦នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់ទះ ៦នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់ទះ៣នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់ទះ ៨នាក់ /១ទីលាន |
| - | ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស១នាក់/១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់/១ទីលាន |
| - | ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ |
| | **៣.ផ្នែកបាល់បោះ** | | | |
| - | ក្រុមរៀបចំទីលានបាល់បោះ ៦នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់បោះ ៦នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់បោះ ៦នាក់ /១ទីលាន | -ក្រុមរៀបចំទីលានបាល់បោះ ៨នាក់ /១ទីលាន |
| - | ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស១នាក់/១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស២នាក់/១ទីលាន |
| - | ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ |
| | **៤.ផ្នែកអត្តពលកម្ម** | | | |
| - | ក្រុមរៀបចំទីលានអត្តពលកម្ម ៨នាក់ /១ទីលាន | -ក្រុមរៀបចំទីលានអត្តពលកម្ម៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានអត្តពលកម្ម៣នាក់ /១ទីលាន | -ក្រុមរៀបចំទីលានអត្តពលកម្ម ៨នាក់/១ទីលាន |
| - | ក្រុមរៀបឧបករណ៍បច្ចេកទេស ៤នាក់ /១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស៤នាក់/១ទីលា | -ក្រុមរៀបឧបករណ៍បច្ចេកទេស១នាក់/១ទីលាន | -ក្រុមរៀបឧបករណ៍បច្ចេកទេស ៤នាក់/១ទីលាន |
| - | ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ |
| | **៥.វិញ្ញាសាដទៃទៀត** | | | |
| | | | | -ក្រុមរៀបចំទីលាន ៨នាក់/១ទីលាន |
| | | | | -ក្រុមរៀបឧបករណ៍បច្ចេកទេស៤នាក់/១ទីលាន |
| | | | | -ក្រុមរៀបចំវេទិកាបើកនិងបិទ ២នាក់ |
| ឃ | **.អនុគណៈកម្មការសុខភាព** | | | |
| | **១.ផ្នែកបាល់ទាត់** | | | |
| - | សង្គ្រោះបឋម៤នាក់ /១ទីលាន | -សង្គ្រោះបឋម៤នាក់ /១ទីលាន | -សង្គ្រោះបឋម៤នាក់ /១ទីលាន | -សង្គ្រោះបឋម៤នាក់ /១ទីលាន |
| - | ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ |
| | **២.ផ្នែកបាល់ទះ** | | | |
| - | សង្គ្រោះបឋម ១ នាក់ /១ទីលាន | -សង្គ្រោះបឋម ១ នាក់ /១ទីលាន | -សង្គ្រោះបឋម ១ នាក់ /១ទីលាន | -សង្គ្រោះបឋម ១នាក់ /១ទីលាន |
| - | ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ | -ក្រុមត្រួតពិនិត្យដូភីងនិងយេនឌ័រ២នាក់ |
| | **៣.ផ្នែកបាល់បោះ** | | | |

| | | | | |
|---|---|---|---|---|
| | - សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១នាក់ /១ទីលាន |
| | - ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ |
| | **៤_ផ្នែកអត្តពលកម្ម** | | | |
| | - សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១ នាក់ /១ទីលាន | -សង្គ្រោះចល័ត ១ នាក់ /១ទីលាន |
| | - ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ |
| | **៥_ផ្នែកវិញ្ញាសាដទៃទៀត** | | | |
| | - សង្គ្រោះចល័ត យ៉ាងច្រើន០៣នាក់ | -សង្គ្រោះចល័ត យ៉ាងច្រើន០៣នាក់ | -សង្គ្រោះចល័ត យ៉ាងច្រើន០៣នាក់ | -សង្គ្រោះចល័ត យ៉ាងច្រើន០៣នាក់ |
| | - ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ |
| | **៥_ពេទ្យប្រចាំការតាមមណ្ឌលស្នាក់នៅរបស់កីឡាករ** | | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ | -ក្រុមគ្រូពេទ្យពិនិត្យដូពីងនិងយ៉េនឌ័រ២នាក់ |
| | - ២នាក់/ ១ មណ្ឌល | - ២នាក់ / ១ មណ្ឌល | - ២នាក់ / ១ មណ្ឌល | - ២នាក់ / ១ មណ្ឌល |
| ង | **_អនុគណៈកម្មការបដិសណ្ឋារកិច្ច ពត៌មាន និង ស្នាក់នៅ** | | | |
| | - ក្រុមបើក-បិទ ពិធីការ និង ស្នាក់នៅ យ៉ាង ច្រើន ២០នាក់ | ក្រុមបើក-បិទ ពិធីការ និង ស្នាក់នៅ យ៉ាង ច្រើន ២០នាក់ | ក្រុមបើក-បិទ ពិធីការ និង ស្នាក់នៅ យ៉ាង ច្រើន ២០នាក់ / ក្នុង១មណ្ឌល | ក្រុមបើក-បិទ ពិធីការ និង ស្នាក់នៅ យ៉ាង ច្រើន ២០នាក់ |
| | - ក្រុមពត៌មានយ៉ាងច្រើន៨នាក់ | ក្រុមពត៌មានយ៉ាងច្រើន៥នាក់ | ក្រុមពត៌មានយ៉ាងច្រើន ៣នាក់/ក្នុង១ មណ្ឌល | ក្រុមពត៌មានយ៉ាងច្រើន ៦នាក់ |
| ច | **_អនុគណៈកម្មការហិរញ្ញវត្ថុ** | | | |
| | -ក្រុមគណនេយ្យ១នាក់/កីឡាករ៣០០នាក់ | -ក្រុមគណនេយ្យ១នាក់ /កីឡាករ៣០០នាក់ | -ក្រុមគណនេយ្យ២នាក់ | -ក្រុមគណនេយ្យ១នាក់ /កីឡាករ១៨០នាក់ |
| | -ក្រុមសំភារៈរង្វាន់១នាក់/កីឡាករ៤០០នាក់ | -ក្រុមសំភារៈរង្វាន់១នាក់/កីឡាករ៤០០នាក់ | -ក្រុមសំភារៈរង្វាន់ ២នាក់ | -ក្រុមសំភារៈរង្វាន់១នាក់ /កីឡាករ២០០នាក់ |
| | -ក្រុមដឹកជញ្ជូន ១នាក់/កីឡាករ៣០០នាក់ | -ក្រុមដឹកជញ្ជូន ១នាក់ /កីឡាករ៣០០នាក់ | | -ក្រុមដឹកជញ្ជូន ១នាក់ /កីឡាករ ៥០នាក់ |
| | **វិញ្ញាសាដទៃទៀត** | | | |
| | | | | -ក្រុមគណនេយ្យក្នុងមួយទីលាន០៣នាក់ |
| | | | | -ក្រុមសំភារៈរង្វាន់ក្នុងមួយទីលាន០៣នាក់ |
| | | | | -ក្រុមដឹកជញ្ជូន ក្នុងមួយទីលាន០៣នាក់ |
| ឆ | **_អនុគណៈកម្មការសន្តិសុខ** | | | |
| | យ៉ាងច្រើន៣០នាក់ដែលចែកជា : | យ៉ាងច្រើន៣០នាក់ ដែលចែកជា : | យ៉ាងច្រើន២៤នាក់ ដែលចែកជា : | យ៉ាងច្រើន២៦នាក់ ដែលចែកជា : |
| | -ក្រុមសណ្តាប់ធ្នាប់ទីលានប្រកួត | -ក្រុម សណ្តាប់ធ្នាប់ទីលានប្រកួត | -ក្រុមសណ្តាប់ធ្នាប់ទីលានប្រកួត | -ក្រុមសណ្តាប់ធ្នាប់ទីលានប្រកួត |
| | -ក្រុមសណ្តាប់ធ្នាប់កន្លែងស្នាក់នៅ | -ក្រុម សណ្តាប់ធ្នាប់កន្លែងស្នាក់នៅ | -ក្រុមសណ្តាប់ធ្នាប់កន្លែងស្នាក់នៅ | -ក្រុមសណ្តាប់ធ្នាប់កន្លែងស្នាក់នៅ |
| | -ក្រុមសណ្តាប់ធ្នាប់ពេលបើកនិងបិទពិធី | -ក្រុម សណ្តាប់ធ្នាប់ពេលបើកនិងបិទពិធី | -ក្រុមសណ្តាប់ធ្នាប់ពេលបើកនិងបិទពិធី | -ក្រុមសណ្តាប់ធ្នាប់ពេលបើកនិងបិទពិធី |

## ជំពូកទី ៤

## ប្រាក់បំប៉ន និង ប្រាក់ឧបត្ថម្ភ ចំពោះការប្រមូលផ្តុំហ្វឹកហ្វឺន

**ប្រការ ៨ :** កីឡាករជំរើសជាតិ គឺជាកីឡាករដែលមានកំរិតបច្ចេកទេសខ្ពស់ ហើយត្រូវបានជ្រើសរើសដោយគណៈកម្មការបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និង កីឡា សហការជាមួយសហព័ន្ធកីឡាជាតិ ក្រោយពីបានឆ្លងកាត់ការប្រកួតជ្រើសរើសជើងឯក ប្រចាំឆ្នាំនីមួយៗកន្លងមក ។ ចំនួនវិញ្ញាសា កីឡាករ អនុរក្ស គ្រូបង្ហាត់ និង រយៈពេលនៃការប្រមូលផ្តុំហ្វឹកហ្វឺន ត្រូវកំណត់ដោយប្រកាសរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ៩ :** ដើម្បីធានាគុណភាពនៃការហ្វឹកហ្វឺនក្នុងរយៈពេលប្រមូលផ្តុំ គ្រូបង្ហាត់ អនុរក្ស និង កីឡាករជំរើសជាតិម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ :

១ - គ្រូបង្ហាត់ ផ្តល់ជូនក្នុងមួយខែ ចំនួន ២០០.០០០រ

២ - អនុរក្ស ផ្តល់ជូនក្នុងមួយខែ ចំនួន ១២០.០០០រ

៣ - កីឡាករ ផ្តល់ជូនក្នុងមួយខែ ចំនួន ១២០.០០០រ

សំរាប់ចំណាយផ្សេងៗផ្ទាល់ខ្លួន ។ គ្រូបង្ហាត់ អនុរក្ស និង កីឡាករជំរើសជាតិម្នាក់ៗ ត្រូវទទួលការបំប៉នដែលមានតំលៃស្មើនឹង ១៥.០០០រ ក្នុងមួយថ្ងៃ បន្ថែមទៀត ។

## ជំពូកទី ៥

## ប្រាក់ឧបត្ថម្ភ និង ប្រាក់អមរង្វាន់សំរាប់កីឡាករជ័យលាភី និង ប្រាក់ឧបត្ថម្ភ មន្ត្រីជំនាញបច្ចេកទេស

**ប្រការ ១០ :** **ប្រាក់ឧបត្ថម្ភកីឡាករក្នុងប្រទេសត្រូវបានកំណត់ដូចខាងក្រោម :**

ក- ប្រាក់ឧបត្ថម្ភហូបចុកប្រតិភូ និង កីឡាករក្នុងរយៈពេលប្រកួត៨.០០០រ/១នាក់/១ថ្ងៃ ។

ខ- ប្រាក់ឧបត្ថម្ភហូបចុកប្រតិភូ និង កីឡាករក្នុងពេលធ្វើដំណើរ ត្រូវគិតក្នុងមួយថ្ងៃ៨.០០០រ០០ គុណនឹងចំនួនប្រតិភូនិងកីឡាករចូលរួម គុណនឹងចំនួនថ្ងៃធ្វើដំណើរ ។ ដោយឡែកចំពោះខេត្ត-ក្រុងរៀបចំការប្រកួតផ្តល់ជូនតែអ្នកឆ្លងស្រុកចំនួន៨.០០០រក្នុងមួយនាក់ សំរាប់ពេលធ្វើដំណើរ ។

**គ- ប្រាក់ឧបត្ថម្ភក្រុមចូលរួមប្រកួត ( សំរាប់ប្រកួតទូទាំងប្រទេស )**

-ក្រុមបាល់ទាត់ ខេត្តវាលរាប ផ្តល់ជូន ១ ក្រុម ចំនួន ៧០០.០០០រ០០

-ក្រុមបាល់ទះ ខេត្តវាលរាប ផ្តល់ជូន ១ ក្រុម ចំនួន ៥០០.០០០រ០០

-ក្រុមបាល់បោះ ខេត្តវាលរាប ផ្តល់ជូន ១ ក្រុមចំនួន ៥០០.០០០រ០០

-ក្រុមអត្តពលកម្ម ខេត្តវាលរាប ផ្តល់ជូន ១ ក្រុមចំនួន ៥០០.០០០រ០០

-ក្រុមបាល់ទាត់ ខេត្តជាប់ស្រយាល ផ្តល់ជូន ១ ក្រុម ចំនួន ៩០០.០០០រ០០

-ក្រុមបាល់ទះ: ខេត្តដាច់ស្រយាល ផ្តល់ជូន ១ ក្រុម ចំនួន ៦០០.០០០៛០០

-ក្រុមបាល់បោះ ខេត្តដាច់ស្រយាល ផ្តល់ជូន ១ ក្រុមចំនួន ៦០០.០០០៛០០

-ក្រុមអត្តពលកម្ម ខេត្តដាច់ស្រយាល ផ្តល់ជូន ១ ក្រុមចំនួន ៦០០.០០០៛០០

-ចំពោះប្រាក់ឧបត្ថម្ភក្រុមលើវិញ្ញាសាដទៃទៀតត្រូវយក៤០.០០០៛០០ គុណនឹងចំនួនកីឡាករចូលរួមប្រកួត ។

**ឃ. ប្រាក់ឧបត្ថម្ភក្រុមចូលរួមប្រកួត ( សំរាប់ប្រកួតនៅតាមភូមិភាគ )**

-ក្រុមបាល់ទាត់ ផ្តល់ជូន ១ ក្រុម ចំនួន ៧០០.០០០៛០០

-ក្រុមបាល់ទះ ផ្តល់ជូន ១ ក្រុម ចំនួន ៥០០.០០០៛០០

-ក្រុមបាល់បោះ ផ្តល់ជូន ១ ក្រុមចំនួន ៥០០.០០០៛០០

-ក្រុមអត្តពលកម្ម ផ្តល់ជូន ១ ក្រុមចំនួន ៥០០.០០០៛០០

**ង. ប្រាក់ឧបត្ថម្ភបន្ថែមចំពោះកីឡាករប្រយុទ្ធក្នុងមួយប្រកួត**

-កីឡាករទទួលជ័យជំនះ ផ្តល់ជូន ១ នាក់ ចំនួន ៤០.០០០៛០០

- កីឡាករចាញ់ ផ្តល់ជូន ១ នាក់ ចំនួន ៣០.០០០៛០០

**ច. ប្រាក់ឧបត្ថម្ភអមរង្វាន់**

**ច.១. កីឡាឯកត្តជន :**

- ចំពោះវិញ្ញាសាត្រឹម១០ គ.មចុះ និង ហែលទឹកត្រឹមចំងាយ៣ គ.មចុះ ផ្តល់ប្រាក់ឧបត្ថម្ភអមរង្វាន់ជ័យលាភី ត្រូវកំណត់ដោយតាមអត្រាដូចខាងក្រោម :

-លេខ១ ផ្តល់ជូន ១៥០.០០០៛០០

-លេខ២ ផ្តល់ជូន ១០០.០០០៛០០

-លេខ៣ ផ្តល់ជូន ៨០.០០០៛០០

-ចាប់ពីលេខ ៤ រហូតដល់លេខ ១០ ( យោងតាមបទបញ្ជានៃការប្រកួតជាក់ស្តែង ) ត្រូវផ្តល់ជូនក្នុងម្នាក់១ ៤០.០០០៛០០ ស្មើគ្នា ។

-ចាប់ពីលេខ១១ រហូតដល់លេខ ២០ ( យោងតាមបទបញ្ជានៃការប្រកួតជាក់ស្តែង ) ត្រូវផ្តល់ជូនក្នុងម្នាក់១២០.០០០៛០០ ស្មើគ្នា ។

ចំពោះវិញ្ញាសារត់ចំងាយលើសពី ១០ គ.ម និង ហែលទឹកលើសពី ៣គ.ម ប្រាក់ឧបត្ថម្ភជ័យលាភីត្រូវយកអត្រាខាងលើនេះ ទៅគណនាតាមសមាមាត្រនៃរយៈចំងាយ ។

ចំពោះវិញ្ញាសាអត្តពលកម្មដទៃទៀត ផ្តល់ប្រាក់ឧបត្ថម្ភអមរង្វាន់ជ័យលាភី ត្រូវយកតាមអត្រាខាងលើ ។

**ច.២. កីឡារួម :**

ការផ្តល់ប្រាក់ឧបត្ថម្ភអមរង្វាន់ជ័យលាភី ត្រូវកំណត់ដោយគិតតាមអត្រាផ្តល់ប្រាក់ឧបត្ថម្ភ នៃវិញ្ញាសារត់ចំងាយ ១០គ.មចុះ គុណនឹងចំនួនកីឡាករដែលចូលរួមប្រកួតជាក់ ស្តែងក្នុងទីលាន ។

**ច.៣. កីឡាប្រយុទ្ធ :**

ការផ្តល់ប្រាក់ឧបត្ថម្ភអមរង្វាន់ជ័យលាភី ត្រូវកំណត់ដោយគិតតាមអត្រាផ្តល់ប្រាក់ឧបត្ថម្ភ នៃ

វិញ្ញាសា វត់ចំងាយ១០គ.ម ចុះ គុណនឹង ២ដង ។

ដោយឡែកអត្រាគិតប្រាក់ឧបត្ថម្ភ សំរាប់អមរង្វាន់ជ័យលាភី ផ្តល់ជូនកីឡាករប្រយុទ្ធ ដែលមានលក្ខណៈជាការសំដែងត្រូវកំណត់យក ៧០% នៃវិញ្ញាសារត់ចំងាយ ១០គ.មចុះ ។

**ច.៤. កីឡាករប្រើប្រាស់ឧបករណ៍ជាយានគ្មានម៉ាស៊ីន :** ទូក កង់ សេះ ។ល។

ការផ្តល់ប្រាក់ឧបត្ថម្ភអមរង្វាន់ជ័យលាភី ត្រូវកំណត់ស្មើនឹងប្រាក់ឧបត្ថម្ភ ចំពោះវិញ្ញាសារត់ចំងាយ ១០ គ.ម ចុះ គុណនឹងចំនួនកីឡាករដែលចូលរួមប្រកួតជាក់ស្តែងក្នុងទីលាន ។

**ប្រការ ១១ :** ការចេញទៅប្រកួតនៅក្រៅប្រទេស របស់ប្រតិភូ និង កីឡាករជំរើសជាតិគ្រប់វិញ្ញាសា និង គ្រប់កីរិត ត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និង កីឡា ដែលជាអាណាព្យាបាល នឹង ត្រូវទទួលប្រាក់ឧបត្ថម្ភចំណាយតាមលទ្ធភាពនៃថវិកា ។

**ប្រការ ១២ :** ប្រាក់រង្វាន់សរសើរសំរាប់កីឡាករ ដែលទទួលជ័យលាភីក្នុងការប្រកួតជាអន្តរជាតិ លក្ខណៈហ្លេម

**ក. ប្រាក់សំរាប់ប្រកួតជាលក្ខណៈឯកត្តជន :**

**ក.១. ប្រកួតកីឡាថ្នាក់តំបន់**

១-មេដាយមាស ផ្តល់ជូន ៦.០០០.០០០៛០០

២-មេដាយប្រាក់ ផ្តល់ជូន ៤.០០០.០០០៛០០

៣-មេដាយសំរិទ្ធិ ផ្តល់ជូន ៣.០០០.០០០៛០០

**ក.២. ប្រកួតកីឡាថ្នាក់ទ្វីប**

១-មេដាយមាស ផ្តល់ជូន ១០.០០០.០០០៛០០

២-មេដាយប្រាក់ ផ្តល់ជូន ៧.០០០.០០០៛០០

៣-មេដាយសំរិទ្ធិ ផ្តល់ជូន ៥.០០០.០០០៛០០

**ក.៣. ប្រកួតកីឡាពិភពលោក**

១-មេដាយមាស ផ្តល់ជូន ១៤.០០០.០០០៛០០

២-មេដាយប្រាក់ ផ្តល់ជូន ១០.០០០.០០០៛០០

៣-មេដាយសំរិទ្ធិ ផ្តល់ជូន ៧.០០០.០០០៛០០

**ខ. ប្រាក់រង្វាន់សំរាប់ការប្រកួតជាក្រុម:**

ការផ្តល់ប្រាក់រង្វាន់ជាក្រុមត្រូវយករង្វាន់ឯកកត្តជន គុណនឹងចំនួនកីឡាករចូលរួមជាក់ស្តែង ។

**ប្រការ ១៣ :**

**ក.** ចំនួនថ្ងៃធ្វើការរបស់គណៈកម្មការទទួលបន្ទុករួម ត្រូវគិតបន្ថែមមួយថ្ងៃមុនការប្រកួត និងមួយថ្ងៃក្រោយការប្រកួត ។

**ខ.** ចំនួនថ្ងៃរបស់គណៈកម្មការរៀបចំការប្រកួត ត្រូវគិតបន្ថែមមួយថ្ងៃមុនការប្រកួត ។

**គ.** ចំនួនថ្ងៃប្រកួត ត្រូវកំណត់ពេលវេលាមិនឱ្យលើសពី ១៥ ថ្ងៃ ។ល។

ប្រការ ១៤ :

ក- គណៈកម្មការ និង អនុគណៈកម្មការ មន្ត្រីជំនាញបច្ចេកទេស និង មន្ត្រីពាក់ព័ន្ធដទៃទៀតដែលមានចែងក្នុងលិខិតឧទ្ទេសនាមដោយក្រសួង ត្រូវបានប្រាក់ឧបត្ថម្ភដូចខាងក្រោម :

- ៣៨,០០០រ០០/១នាក់/១ថ្ងៃ សំរាប់មន្ត្រីធ្វើការក្នុងខេត្ត/ក្រុង
- ៦១,០០០រ០០/១នាក់ /១ថ្ងៃ សំរាប់មន្ត្រីធ្វើការឆ្លងខេត្ត/ក្រុង

ខ- ចំពោះកងកម្លាំងប្រដាប់អាវុធ និង កម្មករ ដែលចាត់តាំងឱ្យចូលរួម សំរាប់ការពារសុវត្ថិភាព និង សំអាតទីលាន ក្នុងពេលប្រកួតកីឡានីមួយៗ ត្រូវផ្ដល់ប្រាក់ឧបត្ថម្ភជារបបម៉ៅការ យ៉ាងច្រើនចំនួន ៤០០,០០០រ០០ ក្នុងមួយទីលានប្រកួតតូច និង យ៉ាងច្រើនចំនួន៦០០,០០០រ០០ ក្នុងមួយទីលានប្រកួតធំ ។

គ- សោហ៊ុយធ្វើដំណើរទៅមកខេត្ត/ក្រុង ត្រូវផ្ដល់ជូនទៅតាមតម្លៃជាក់ស្តែង ។

ប្រការ ១៥ : អាជ្ញាកណ្ដាលបាល់ទាត់០៣ នាក់ និង អាជ្ញាកណ្ដាលបាល់បោះ០២ នាក់ ត្រូវបានទទួលប្រាក់បន្ថែម ៥,០០០រ០០/១នាក់ ក្នុងមួយពេលប្រកួត ។

ប្រការ ១៦ : -ការឧបត្ថម្ភគណៈកម្មការ អនុគណៈកម្មការនានា អ្នកជំនាញបច្ចេកទេសអន្តរជាតិ ក្នុងការប្រកួតជាលក្ខណៈអន្តរជាតិក្នុងប្រទេស បើគ្មានការទ្រទ្រង់ថវិកា តាមនិយាមបរទេស ពីអង្គការអន្តរជាតិ ឬអ្នកទ្រទ្រង់ក្នុងស្រុកទេ ត្រូវសុំគោលការណ៍ដោយឡែកពីរាជរដ្ឋាភិបាល ។

-ថវិកាដែលបានឧបត្ថម្ភពីសប្បុរសជន ឬ អង្គការនានា ( ក្រៅ និង ក្នុងប្រទេស ) សំរាប់ការប្រកួតត្រូវចាត់ទុកជាចំណែកថវិកាសំរាលបន្ទុកថវិការដ្ឋ សំរាប់ចំណាយក្នុងតំរោងប្រកួត ដែលចែងដោយប្រកាសនេះ ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

ប្រការ ១៧ : អង្គភាពជំនាញដែលទទួលខុសត្រូវ ក្នុងការប្រកួតកីឡានិមួយៗ ត្រូវបំពេញការងារជំនួយផ្សេងៗទៀតក្នុងមុខងារ និង ភារកិច្ចប្រចាំថ្ងៃនៃអង្គភាពរបស់ខ្លួន ដែលបានកំណត់ដើម្បីបង្កលក្ខណៈដល់ការប្រកួតទាំងការរៀបចំលិខិតស្នាមរដ្ឋបាល និង ដោះស្រាយសំរបសំរួលការងារ និង ផ្ដល់ពត៌មានផ្សេងៗ ដោយពុំចាំបាច់បង្កើតគណៈកម្មការ ឬ អនុគណៈកម្មការផ្សេងៗទៀតឡើយ ។

ប្រការ ១៨ : ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ដែលបានចាត់តាំង ឱ្យចូលរួមនៅក្នុងគណៈកម្មការប្រកួតកីឡានានា អាចទទួលប្រាក់ឧបត្ថម្ភបានតែម្តងគត់ ក្នុងការប្រកួតកីឡាមួយលើក ឬ ការប្រកួតច្រើនលើក បើពេលវេលាធ្វើការត្រួតគ្នា ។

ប្រការ ១៩ : ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ មិនត្រូវទទួលបានប្រាក់បេសកកម្ម ចំពោះការងារចុះពិនិត្យ ឬ ធ្វើការងារផ្សេងៗ ក្នុងដំណើរការប្រកួតកីឡានានា ក្រៅពីគណៈកម្មការដែលបានកំណត់ នៅក្នុងប្រកាសអន្តរ

Brakas2

ក្រសួងនេះ លើកលែងតែមានបាតុភាពមិនប្រក្រតី ដែលមានអំណះអំណាងច្បាស់លាស់ថា គណៈកម្មការដែលចាត់តាំងឡើងតាមប្រកាសអន្តរក្រសួងនេះ មិនអាចដោះស្រាយបាន ទើបអាចចាត់តាំងគណៈកម្មការពិសេសមួយ ដើម្បីដោះស្រាយបាតុភាពនោះ និង ត្រូវភ្ជាប់មកជាមួយនូវ របាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃដំណោះស្រាយ ទើបអាចទូទាត់ប្រាក់បេសកកម្មបាន ។

**ប្រការ ២០ :** មុខចំណាយលើទំនិញ និង សេវាបំរើឱ្យការប្រកួត ដែលមិនបានកំណត់ក្នុងប្រកាសនេះ ត្រូវអនុវត្តការចំណាយតាមនីតិវិធី ហិរញ្ញវត្ថុជាធរមាន ។

**ប្រការ ២១ :** ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២២ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា |
| រដ្ឋមន្ត្រីស្តីទី | |
| អ៊ុក រ៉ាប៊ុន | តូល.លាះ |

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "

-អាជ្ញាធរសវនកម្មជាតិ " ដើម្បីជូនជ្រាប "

-ដូចប្រការ ២២ " ដើម្បីមុខការ "

-ឯកសារ -កាលប្បវត្តិ